ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

easy speaking MONSOON Paper Tiger

**កិច្ចព្រមព្រៀងព្យួរការងារ**

**របស់**

**បុគ្គលិក និង និយោជក លើកទី ៦**

**ចំនួន ៨២ នាក់ ដែលមានស្រី ចំនួន ៤៦ នាក់**

ដោយសារស្ថានភាពប្រទេសកម្ពុជា ក៏ដូចជាពិភពលោក កំពុងប្រឈមវិបត្តិរងគ្រោះដោយជម្ងឺប៉ះពាល់ប្រព័ន្ធផ្លូវដង្ហើម (Covid19) ហើយបានធ្វើអោយបណ្តារប្រទេសនានាជុំវិញពិភពលោក បានបិទជើងហោះហើរការធ្វើដំណើររបស់ភ្ញៀវទេសចរ ក៏ដូចជាប្រជាជនរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនិងជម្ងឺ Covid19 បានធ្វើអោយប្រទេសកម្ពុជា យើងទទួលផលប៉ះពាល់ស្ទើរទាំងស្រុងដែលមិនមានភ្ញៀវទេសចរ ធ្វើដំណើរចូលមកទស្សនា ឬលេងកំសាន្តនោះទេ ។

ដោយស្ថានភាពនេះបានបង្ករអោយក្រុមហ៊ុន **ម៉ុនស៊ូន អេស៊ាន ប៊ីស្ត្រូ** ( MONSOON ASIAN BISTRO ) យើងមិនអាចដំណើរការអាជីវកម្មរបស់ខ្លួនបាន ដូច្នេះសម្រេចធ្វើកិច្ចព្រមព្រៀងដូចខាងក្រោម៖

**ប្រការ ១៖** ធ្វើការបិទក្រុមហ៊ុន **ម៉ុនស៊ូន អេស៊ាន ប៊ីស្ត្រូ** មួយរយៈពេលចំនួន **៦០** ថ្ងៃដោយគិត ចាប់ពី **ថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០២១ រហូតដល់ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២១ ។**

**ប្រការ២៖** បុគ្គលិកទាំងអស់ដែលបម្រើការងារអោយក្រុមហ៊ុន **ម៉ុនស៊ូន អេស៊ាន ប៊ីស្ត្រូ** ត្រូវបានអនុញ្ញាតឲ្យធ្វើការសម្រាកក្នុងរយៈពេលនៃការបិទខាងលើ ដោយមិនទទួលបានប្រាក់សំណង ឬ ឧបត្ថម្ភពីក្រុមហ៊ុននោះឡើយ លើកលែងតែមានការឧបត្ថម្ភពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣៖** នៅពេលក្រុមហ៊ុនបើកដំណើរការអាជីវកម្មរបស់ខ្លួនឡើងវិញ បុគ្គលិកទាំងអស់របស់ក្រុមហ៊ុនត្រូវបានអនុញ្ញាតអោយចូលបម្រើការងារតាមតួនាទី និង មុខតំណែងរបស់ខ្លួនជាធម្មតា ហើយប្រាក់ខែនិងផលប្រយោជន៍ផ្សេងៗរបស់បុគ្គលិកក៏ទទួលបានដោយពុំមានការកាត់ចោលឡើយ ។

**ប្រការ៤៖** បុគ្គលិក ឬ តំណាងអោយបុគ្គលិកបានអាននិងយល់ព្រមលើកិច្ចព្រមព្រៀងនេះដោយការផ្តិតមេដៃដើម្បីធ្វើជាសក្ខីកម្ម ឬ ភស្តុតាងនៃឯកសារគតិយុត្តិ ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ ។

**ប្រការ ៥៖** រាល់សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយពីខ្លឹមសារខាងលើត្រូវទុកជានិរាសករ៍ ។

**សៀមរាបថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ២០២១**

| **តំណាងបុគ្គលិកទី១** | **តំណាងបុគ្គលិកទី២** | **តំណាងអគ្គនាយកក្រុមហ៊ុន** |
| --- | --- | --- |
| ឈ្មោះ: | ឈ្មោះ: | **ចៅ សុខណ្ណា** |

MONSOON
Asian Fusion & Bistro
Siem Reap, Cambodia